# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១៣១/ គ.ជ.ប
០៧

## សេចក្ដីណែនាំ
### ស្ដីពី
### ការពិនិត្យផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតទៅនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត

---

យោង : - ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ ។
- បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ ។
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ ។

ដើម្បីសម្របសម្រួលប្រតិបត្តិការបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត គ.ជ.ប ណែនាំ និង រំលឹក អស់លោក លោកស្រី ប្រធាន គខ/កប គឃ/សប និង គកប ចាត់ចែងអនុវត្តការផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតទៅនឹងរូបពិតរបស់អ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវ បន្ទាប់មកផ្ទៀងផ្ទាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតតាមករណីដូចខាងក្រោម ៖

១- ករណីឈ្មោះត្រូវគ្នា អនុញ្ញាតឱ្យបោះឆ្នោត

២- ករណីឈ្មោះសរសេរខុសគ្នា តែសូរដូចគ្នា អនុញ្ញាតឱ្យបោះឆ្នោត

៣- ករណីឈ្មោះសរសេរខុសគ្នាដោយខុសអក្ខរាវិរុទ្ធបន្តិចបន្តួច ហើយសូរប្រហែលគ្នា អនុញ្ញាតឱ្យបោះឆ្នោត

៤- ករណីឈ្មោះសរសេរខុសគ្នាដោយខុសអក្ខរាវិរុទ្ធ ដូចជា ខ្វះ ឬ លើសស្រៈ ខ្វះ ឬ លើសព្យញ្ជនៈ ខ្វះ ឬ លើសជើងអក្សរ ខ្វះ ឬ លើសវណ្ណយុត្ត នាំឱ្យមានសូរខុសគ្នា នោះត្រូវបន្តពិនិត្យទិន្នន័យផ្សេងទៀតដូចជា ៖
- ភេទ អាយុ និងអាសយដ្ឋានដូចគ្នា អនុញ្ញាតឱ្យបោះឆ្នោត
- ទិន្នន័យពីរដូចគ្នា ក្នុងចំណោមទិន្នន័យទាំងបី (ភេទ អាយុ និងអាសយដ្ឋាន) អនុញ្ញាតឱ្យបោះឆ្នោត
- ក្នុងករណី ទិន្នន័យទាំងបី ខុសគ្នាទាំងស្រុង នោះពុំអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

៥- ករណីឈ្មោះពីរ ឬ ច្រើនដូចគ្នា ឬស្រដៀងគ្នា ត្រូវបន្តពិនិត្យទិន្នន័យផ្សេងទៀត ដើម្បីឱ្យប្រាកដថា ឈ្មោះណាមួយដែលត្រូវអនុញ្ញាតឱ្យបោះឆ្នោត ។

ទទួលបានសេចក្ដីណែនាំនេះ សូមអស់លោក លោកស្រី ប្រធាន គខ/កប គឃ/សប និង គកប យកចិត្តទុកដាក់ផ្សព្វផ្សាយ និងអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៧
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

អ៊ឹម_សួស្ដី